# គម្រោងអនាម័យក្នុងភូមិភ្នំ

## របាយការណ៍សកម្មភាព៖ ការចាប់ផ្តើមគម្រោងសាកល្បងស្តីពីការឧបត្ថម្ភសាងសង់បង្គន់អនាម័យ (ខែកក្កដា ២០១៨)

កម្មវិធីលើកកំពស់ទឹកស្អាត និងអនាម័យអាស៊ីអាគ្នេយ៍ **(WISE)**
ក្រុមការងាររបស់ WISE មានដូចជា៖ អេឌ្រី ហាមីដា, បុត្រ ចំប៉ា, អ៊ីនតាន់ រ៉ាមីតា អាឌីព្រទ្រី, ជូលីវីយូស ប្រាវីរ៉ា, លីម សូជីវិន, ម៉ៅសីណា, ម៉េង សុភាន់, នីកូឡាស, ប៊ូន ធឿន ផាន, ធី យ៉ុក តៀន, យ៉ូស បញ្ញា

ក្រុមការងាររបស់ អង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍមានដូចជា៖
លោក ថៅ គឹមស្រៀង និង អ៊ុំ អេរ៉ូ

ខែតុលាឆ្នាំ ២០១៨

សូមបញ្ចេញយោបល់ និងចែករំលែក៖ ក្រុមការងារយើងខ្ញុំស្វាគមន៍រាល់មិតិយោបល់នានាទាក់ទងនឹងរបាយការណ៍នេះ ក្នុងក្តីរំពឹងថា មតិយោបល់ និងការសន្ទនាបែបស្ថាបនា នឹងអាចឲ្យយើងដឹងកាន់តែច្បាស់ពីបញ្ហាទាក់ទងនឹង អនាម័យ និងទឹកស្អាត *(WASH)* ដែលជាយាន្តជម្រុញឲ្យក្រុមការងារយើង ពង្រឹងសមត្ថភាពបន្ថែមសម្រាប់គម្រោងក្រោយៗទៀត។ រាល់ពេលបញ្ចេញមតិយោបល់ សូមលោកអ្នកប្រកាន់ខ្ជាប់នូវការគោរព និងឲ្យត្រូវប្រធានបទ។ សូមអរគុណ*!* សូមអរគុណ*!* ក្រុមការងារ វ៉ាយស៍



Powered by

# សេចក្តីអំណរគុណ

ក្រុមការងារ វ៉ាយស៍ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍសូមថ្លែងអំណរគុណដល់៖

- ប្រជាពលរដ្ឋក្នុងភូមិភ្នំ ចំពោះកិច្ចសហការណ៍ក្នុងគម្រោងសាងសង់បង្គន់អនាម័យនេះ និងសេចក្តីអំណត់របស់ប្រជាពលរដ្ឋទាំងអស់គ្នាតាំងពីដំណាក់កាលសិក្សារគ្រោងគម្រោងលើកដំបូង។
- គ្រួសាររបស់លោកអនុភូមិ ចំពោះការទទួលឲ្យក្រុមការងារយើងខ្ញុំស្នាក់ក្នុងភូមិភ្នំ អំឡុងពេលប្រតិបត្តិការណ៍គម្រោង។
- ក្រុមព្រឹក្សាឃុំព្រះផ្ទាត់ ចំពោះការជ្រុំជ្រែង និងទំនុកទុកចិត្តលើក្រុមការងារយើងក្នុងការសម្រេចគម្រោងភូមិភ្នំនេះ បានយ៉ាងមានប្រសិទ្ធភាព។
- មូលនិធិយុវជន អាស៊ាន សាំងហ្គាពួរ (Singapore-ASEAN Youth Fund) [នៃ ក្រុមព្រឹក្សាជាតិយុវជន (National Youth Council)] សម្រាប់ការផ្តល់ជំនួយជាទឹកប្រាក់ ៧,០០០ ដុល្លារសាំងហ្គាពួរ ព្រមទាំងសប្បុរសជនទាំងអស់ ដែលបានចូលរួមវិភាគទានតាមរយៈ[គេហទំព័រ Chuffed.org]។
- និស្សិតនៃសាលាសាំងហ្គាពួរ អាមេរិកាំង ចំពោះការផ្តល់គំនិតនានាទាក់ទងនឹងការលើកទឹកចិត្តឲ្យប្រជាពលរដ្ឋចូលរួមបង់ប្រាក់មកវិញ។
- ក្រុមកាងារស្ម័គចិត្តទាំងអស់គ្នា សម្រាប់ការខំប្រឹងប្រែងអនុវត្តរាល់សម្មភាព និងជាពិសេសសម្រាប់ការខំប្រឹងប្រែងធ្វើការយ៉ាងសស្រោកសស្រាំក្នុងការបកប្រែភាសារ ធ្វើដំណើរ ថតរូបនិងវីឌីអូ និងសកម្មភាពតាមបណ្តាញសង្គមនានា រួមទាំងសកម្មភាពផ្សេងៗទៀតផងដែរ។ យើងសង្ឃឹមថា បុគ្គលិកស្ម័គចិត្តទាំងអស់គ្នានឹងពេញចិត្តនូវបទពិសោធន៍ដែលបានទទួលបាននេះ។

# សេចក្តីសង្ខេប

ភូមិភ្នំស្ថិតក្នុងស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ ប្រទេសកម្ពុជា ហើយប្រជាជនក្នុងភូមិទទួលបានការយល់ដឹងពីអនាម័យតិចតួចបំផុត បើប្រៀបនឹងភូមិដទៃទៀតក្នុងឃុំព្រះធាតុ។ គិតពីខែមិថុនាឆ្នាំ ២០១៦ អត្រាទទួលបានអនាម័យក្នុងភូមិភ្នំមានត្រឹមតែ ២៩% តែប៉ុននោះ (ឬ ២៩ ក្នុងចំណោម ១០១ គ្រួសារ)។ ក្រុមការងារ វ៉ាយស៍ សម្រេចដោះស្រាយបញ្ហាអនាម័យក្នុងភូមិភ្នំ ដោយយោងទៅតាមការស្នើរសុំរបស់ប្រជាពលរដ្ឋក្នុងការសាងសង់បង្គន់អនាម័យ។ ដូច្នេះគោលបំណងនៃគម្រោងនេះគឺដើម្បីកែលម្អអនាម័យ និងទំលាប់រស់នៅស្អាតរបស់ប្រជាជន តាមរយៈការសាងសង់បង្គន់អនាម័យ ដែលមានគុណភាពសមរម្យ និងកែរប្រែទម្លាប់រស់នៅមិនស្អាតរបស់ប្រជាពលរដ្ឋ។ សិក្ខាសាលាស្តីពីផែនការគម្រោង ត្រូវបានអនុវត្តក្នុងខែតុលាឆ្នាំ ២០១៧ ដោយក្នុងនោះ យើងសម្រេចបានគម្រោងព្រៀងផែនការឧបត្ថម្ភសម្រាប់ការសាងសង់បង្គន់អនាម័យ ដែលទទួលបានការយល់ព្រមពីប្រជាពលរដ្ឋ។ ជំហានបន្ទាប់របស់ វ៉ាយស៍ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ គឺសាកល្បងគម្រោងឧបត្ថម្ភថវិការសង់បង្គន់អនាម័យ ជូនដល់ប្រជាពលរដ្ឋប្រាំ(៥)គ្រួសារ។

សេចក្តីសង្ខេបសកម្មភាព

ចាប់ពីថ្ងៃទី ១ ដល់ ១៤ ខែកក្កដាឆ្នាំ ២០១៨ ក្រុមការងាររបស់ វ៉ាយស៍ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ បានចុះមកផ្ទាល់ដល់ភូមិភ្នំ ដើម្បីបើកដំណើរការគម្រោងការឧបត្ថម្ភសម្រាប់ការសាងសង់បង្គន់អនាម័យ។ ក្រុមការងារបានចេញពីភូមិភ្នំ មុនពេលបង្គន់ត្រូវបានសាងសង់រួចរាល់ តែក្រុមការងាររបស់អង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍនៅបន្តមើលការខុសត្រូវសាងសង់រហូតទាល់តែបង្គន់អាចប្រើប្រាស់បាន។

<u>ការផ្សព្វផ្សាយពីគម្រោងឧបត្ថមសង់បង្គន់ដល់ប្រជាពលរដ្ឋ</u>

ក្រុមការងារ វ៉ាយស៍ និងអង្គការនាគព័ន្ធសម្រាប់ការភិវឌ្ឍ បានចុះតាមគ្រួសារនីមួយៗដើម្បីពន្យល់ពីគម្រោង និងអញ្ជើញគ្រួសារទាំងនោះដាក់ពាក្យសុំការឧបត្ថម្ភ។ ជាលទ្ធផល មាន១៤ គ្រួសារបានដាក់ពាក្យសុំការឧបត្ថម្ភ។

<u>ការជ្រើសរើសគ្រួសារដែលទទួលបានការឧបត្ថម្ភ</u>

ក្រុមការងារ វ៉ាយស៍ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍបានសម្ភាសន៍ ១៤ គ្រួសារ និងបានជ្រើសរើសគ្រួសារដែលអាចទទួលបានការឧបត្ថម្ភ តាមរយៈដំណើរការបីដំណាក់កាល៖ ដំណាក់កាលទី១៖ ជម្រុះក្រុមគ្រួសារណាដែលមិនស្របនឹងលក្ខណខ័ណ្ឌជ្រើសរើស ។ ទី ២៖ បោះឆ្នោតជ្រើសយក ៥ គ្រួសារ៖ ទី៣៖ បោះឆ្នោតជ្រើសថាតើគ្រួសារណា ដែលគួរទទួលយក ការឧបត្ថម្ភ ៨0% ឬ ១០០ %។ បន្ទាប់ពីជូនដំណឹងបេក្ខជនទាំងអស់ពីលទ្ធផល ក្រុមការងារ វ៉ាយស៍ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ បានរៀបចំពិធីចុះហត្ថលេខា ដើម្បីឲ្យគ្រួសារដែលនឹងទទួលការឧបត្ថម្ភចុះកិច្ចព្រមព្រៀង។ លោកប្រធានភូមិធ្វើជាសាក្សីពិធីចុះហត្ថលេខា ។

<u>ការសាងសង់បង្គន់អនាម័យ</u>

មានតែជាងសង់បង្គន់តែម្នាក់ (១) ដែលព្រមសាងសង់បង្គន់អំឡុងនេះ។ ក្រុមការងារ វ៉ាយស៍ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍបានយល់ព្រមសាងសង់បង្គន់ ដែលធ្វើពីបេតុង និងចានបង្គន់សេរ៉ាមិច និងអាងទឹកបេតុងមួយ ស៊ុមឈើ ជញ្ជាំង និងដំបូលស័ង្កសី និងអាងស្តុកកាកសំណល់ជីកក្រោមដី ដែលមានប្រវែងបីខ្នោះ។ ហើយបង្គន់នីមួយៗមានតម្លៃប្រហែល ៣០០ ដុល្លាអាមេរិក។ លើកលែងតែករណីរបស់អ្នកស្រី ស៊ីណា ដែលត្រូវប្រើរទេះជនពិការ ។ ក្រុមការងារ វ៉ាយស៍ បានកែរសម្រួលរូបរាងបង្គន់អនាម័យ ឲ្យសមស្របនឹកលក្ខណ និងការចង់បានរបស់ស៊ីណា និងអ្នកដែលត្រូវថែគាត់។ បង្គន់របស់ស៊ីណាចំណាយប្រាក់សរុប ៤០០ ដុល្លាអាមេរិក។

ខណៈពេលដែលកំពុងសាងសង់បង្គន់ ក្រុមការងារអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍក៏បានចែករំលែកចំណេះដឹងអំពីការប្រើប្រាស់ និងរក្សាបង្គន់ឲ្យបានត្រឹមត្រូវ ជូនដល់គ្រួសារនីមួយៗ។

<u>លក្ខខណ្ឌបង់សង</u>

មានពីរគ្រួសារ ដែលបានបង់វិភាគទានជាមុន ហើយពីរគ្រួសារទៀតបាននឹងបង់ប្រាក់សង់បង្គន់ក្នុងរយៈពេលប៉ុន្មានខែក្រោយ។ គ្រួសារទាំងពីរនោះបានយល់ព្រមប្រអប់សន្សំប្រាក់ ដែល វ៉ាយស៍ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍបានផ្តល់ជូន។

បញ្ហាប្រឈម និងការកែលម្អ

ក្រុមការងារ វ៉ាយស៊ិ ជួបប្រទះបញ្ហាប្រឈមជាច្រើន ដែលប៉ះពាល់ដល់លទ្ធផលរបស់សកម្មភាពការងារក្នុងភូមិភ្នំ។

- បញ្ហាចំបងគឺ យើងមិនមានក្រុមការងារគ្រប់គ្រាន់នៅក្នុងសហគមន៍ ជាពិសេសអំឡុងពេលពីរសប្តាហ៍ក្រោយពីការដាក់សម្ពោធគម្រោង។ ពេលនោះក្រុមការងារអនុវត្តន៍គម្រោងបានពឹងផ្អែកលើក្រុមការងារនៅសេសសល់ ក្នុងការទាក់ទងជាមួយប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធនានា។
- សកម្មភាពខ្លះបានអនុវត្តអំឡុងពេលឃោសនាបោះឆ្នោត ដែលអាចប៉ះពាល់ដល់ទស្សនយល់ឃើញលើអព្យាក្រឹតភាព និងឯករាជភាពរបស់ វ៉ាយស៊ិ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ។
- អំឡុងពេលនេះ មានតែជាងសាងសង់តែម្នាក់ ដែលព្រមនឹងសង់បង្គន់ដែលសមស្របនឹងលក្ខណត្រូវការរបស់ វ៉ាយស៊ិ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ។ ការប្រឈមនេះបានដាក់សម្ពាធដល់ក្រុមការងារ ដោយមិនអាចជ្រើសរើសជាងផ្សេងទៀតដែលមានបទពិសោធន៍ និងមិនអាចចរចារតម្លៃបាន។

ដោយនេះជាបទពិសោធន៍ទីមួយ ដែលយើងអនុវត្តគម្រោងឧបត្ថម្ភសង់បង្គន់នេះ ក្រុមការងារ វ៉ាយស៊ិ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ នឹងអាចកែលំអរសេចក្តីពង្រាងគម្រោង និងការអនុវត្តន៍គម្រោងលើកក្រោយ។

ជំហានបន្ទាប់

ក្រោយពីសាងសង់បង្គន់រួចហើយ ក្រុមអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ និងវ៉ាយស៊ិ នឹងចុះតាមគ្រួសារដែលទទួលបានការឧបត្ថម្ភជារៀងរាល់ខែ ដើម្បីប្រមូលប្រាក់បង់ និងត្រួតពិនិត្យមើលការប្រើប្រាស់ និងការរក្សាបង្គន់ ព្រមទាំងប្រមូលពត៌មានទាក់ទងនឹងស្ថានភាពហិរញ្ញវត្ថុ របស់គ្រួសារនីមួយៗ។ ក្រុមការងារ វ៉ាយស៊ិ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ នឹងធ្វើការវាយតម្លៃគម្រោងមួយ នៅពេលណាមួយសមគួរ ក្រោយពីប្រមូលប្រាក់បង់រួចរាល់អស់ហើយ។ ទិន្នន័យប្រមូលបាននឹងជួយឲ្យ វ៉ាយស៊ិ នឹងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ អាចកំណត់ពីលទ្ធភាពនៃគម្រោងឧបត្ថម្ភសាងសង់បង្គន់អនាម័យ និងកំណត់ថាតើយើងគួរពង្រីកគម្រោងដែរឬទេ។

# តារាងមាតិកា


សេចក្តីអំណរគុណ 3

សេចក្តីសង្ខេប 4

តារាងមាតិកា 6

1. សេចក្តីណែនាំ 7

1.1. គោលបំណងរបស់ការអនុវត្តគម្រោង 10

1.2. កាលវិភាគ 10

2. សកម្មភាព 12

2.1. សកម្មភាពមុនចាប់ផ្តើមគម្រោង 12

2.2. ការផ្សព្វផ្សាយពីគម្រោងឧបត្ថមសង់បង្គន់ដល់ប្រជាពលរដ្ឋ 14

2.3. ការជ្រើសរើសគ្រួសារដែលទទួលបានការឧបត្ថម្ភ 16

2.3.1. ការសម្ភាសបេក្ខជន 17

2.3.2. ការជ្រើសរើសគ្រួសារដែលទទួលបានការឧបត្ថម្ភ 18

2.3.2.1. ជម្រុះបេក្ខជនណាដែលមិនគ្រប់លក្ខខណ្ឌ។ 19

2.3.2.2. ជ្រើសរើសបេក្ខជនទទួលការឧបត្ថម្ភប្រាំនាក់ 23

2.3.2.3. ការសម្រេចពីកម្រិតនៃចំនួនឧបត្ថម្ភ 25

2.3.3. ការជូនដំណឹងដល់បេក្ខជន 25

2.3.4. ចុះហត្ថលេខារលើលិខិតព្រមព្រៀង 26

2.4. ការសាងសង់បង្គន់អនាម័យ 27

2.4.1. ការជ្រើសរើសជាងសង់បង្គន់ 27

2.4.2. Design of the latrines 28

2.4.3. Construction 29

2.4.4. Sharing about latrine use and maintenance 32

2.5. លក្ខខណ្ឌបង់សង 32

2.6. Meeting with commune chief 33

3. បញ្ហាប្រឈម និងការកែលម្អ 33

3.1. Key challenges 33

3.2. Constraints 34

3.3. Other lessons learned 34

4. Outcomes 35

5. ជំហានបន្ទាប់ 35

# 1. សេចក្តីណែនាំ

ទីតាំងស្ថិតក្នុងឃុំព្រះធាតុ (ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ប្រទេសកម្ពុជា) (រូបទី ១), ភូមិភ្នំមាន ១០១ គ្រួសារ [1]ត្រូវជា ៥២១នាក់[2]។




រូបភាព ១ ទីតាំងនៃអូររាំងឪស្រុក(ប្រែប្រួលពីផែនទី Google )

ប្រជាជនភូមិភ្នំទទួលបានការយល់ដឹងផ្នែកអនាម័យ តិចតួចក្នុងឃុំ។ នៅពេលដែល វ៉ាយសិ ទៅដល់ភូមិលើកដំបូងក្នុងខែធ្នូឆ្នាំ ២០១៥ មានតែ ១២ គ្រួសារប៉ុននោះមានបង្គន់អនាម័យប្រើ។ ក្រៅពីនោះ មាន ១៧ គ្រួសារបានយកប្រាក់កម្ចីពីមីក្រូហិរញ្ញវត្ថុ វីហ្សិនហ្វាន់ ទៅធ្វើគ្រឹះបង្គន់។ ទោះជាយ៉ាងណាគ្រួសារមួយចំនួនមិនមានលទ្ធភាពសង់សំណង់ខាងលើដោយខ្លួនឯងទេ (រូបភាពទី ២) គិតពីខែមិថុនាឆ្នាំ ២០១៦ អត្រាទទួលបានអនាម័យក្នុងភូមិភ្នំមានតែ ២៩% (ឬ ២៩ គ្រួសារ)។ បើប្រៀបធៀបនឹងឃុំព្រះធាតុទាំងមូល ដែលមានអត្រាទទួលបានអនាម័យរហូតដល់ ៩៥%[៣]។



[1] ក្រុមប្រឹក្សាឃុំ, ខែមិថុនាឆ្នាំ ២០១៦

[2] ប្រធានភូមិ ខែធ្នូឆ្នាំ ២០១៥

រូបភាព ២ បង្គន់អនាម័យមានសំណង់ផ្នែកលើ (មិថុនា ២០១៦)

ក្រុមការងារ វ៉ាយស៍ សម្រេចដោះស្រាយបញ្ហាអនាម័យក្នុងភូមិភ្នំ ព្រោះប្រជាជនដែលបានជួបជាមួយក្រុមការងារកាលពី ខែធ្នូ ២០១៥ បានស្នើសុំឲ្យក្រុមការងារសង់បង្គន់អនាម័យ (រូបភាព ៣)។ ដូច្នេះគោលបំណងនៃគម្រោងនេះគឺដើម្បីកែលម្អអនាម័យ និងទំលាប់រស់នៅស្អាតតាមរយៈការសាងសង់បង្គន់អនាម័យ ដែលមានគុណភាពសមរម្យ និងប្រសិនបើចាំបាច់ត្រូវមានការផ្លាស់ប្តូរឥរិយាបថឲ្យមានអនាម័យ ។ គម្រោងនេះគឺអនុវត្តនៅក្នុងភាពជាដៃគូជាមួយនឹងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ។ បេសកម្មរបស់ អង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍម គឺដើម្បីសហការជាមួយនឹងអង្គការ និងស្ថាប័ន ដែលពាក់ព័ន្ធ ដើម្បីជួយអភិវឌ្ឍសហគមន៍តាមរយៈភាពជាដៃគូដើម្បីដោះស្រាយបញ្ហា និងការព្រួយបារម្ភរបស់សហគមន៍ និងដើម្បីឱ្យប្រជាពលរដ្ឋក្លាយជាពលរដ្ឋមានទំនួលខុសត្រូវក្នុងសង្គម។



រូបភាព ៣
(a)ខាងឆ្វេង៖ ក្រុមការងារ វ៉ាយស៍ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ នៅក្នុងសហគមន៍កំពុងពិភាក្សាតម្រូវការក្នុងភូមិភ្នំ (ខែធ្នូ ២០១៥)
(b)នៅខាងស្តាំ៖ ក្រុមការងារអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ ជួយសម្រួលការពិភាក្សាជាមួយនឹងស្ត្រី អំឡុងពេលការវាយតម្លៃតម្រូវការក្នុងភូមិ (ខែកក្កដា ២០១៦)

ចាប់ពីខែធ្នូ ២០១៥ ក្រុមការងារ វ៉ាយស៍ រួមគ្នាជាមួយនឹង អង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ បានអនុវត្តសកម្មភាពដូចតទៅ៖



រូបភាព ៤ សិក្ខាកាមដែលចូលរួមក្នុងវគ្គសិក្ខាសាលាស្តីពីអនាម័យ និងការរស់នៅស្អាត ធ្វើឡើងពីថ្ងៃទី ២៣ ដល់ ២៥ ខែតុលាឆ្នាំ ២០១៧

- ការស្រាវជ្រាវមូលដ្ឋានគ្រឹះទាក់ទងនឹងការផ្តល់អនាម័យនៅកម្ពុជានិង;
- ការវាយតំលៃតម្រូវការលក្ខខណ្ឌអនាម័យក្នុងភូមិភ្នំក្នុងឆ្នាំ ២០១៦ ដោយសហការជាមួយអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ ដែលត្រូវបានបង្ហាញទៅភូមិភ្នំក្នុងខែតុលាឆ្នាំ ២០១៧។ របាយការណ៍វាយតម្លៃតម្រូវការ មានជាភាសាអង់គ្លេសនិង ខ្មែរ។
- ក្រុមការងារបានចុះដល់សហគមន៍ចាប់ពីថ្ងៃ ២១ ដល់ ២៦ ខែតុលាឆ្នាំ ២០១៧ ដើម្បីធ្វើការជាមួយនឹងអ្នកស្រុកដើម្បីបង្កើតគម្រោងសម្រាប់កែលម្អអនាម័យ និងការរស់នៅស្អាត (រូបភាព ៤)។ ក្រុមការងារ វ៉ាយស៊ិ និងសិក្ខាកាមទាំងអស់បានយល់ព្រមនឹងគម្រោងឧបត្ថម្ភសាងសង់បង្គន់អនាម័យ ដែលអាចឈានដល់ការយល់ព្រមនឹងការអនុវត្តន៍គម្រោងសាកល្បងជូនដល់ ប្រាំក្រុមគ្រួសារ។ របាយការណ៍សកម្មភាពមានទាំងជាអង់គ្លេសនិងខ្មែរ។
- គម្រោងលម្អិតរបស់គម្រោងឧបត្ថម្ភសាងសង់បង្គន់អនាម័យ។ សេចក្តីស្នើគម្រោង និងសៀវភៅមគ្គុទ្ទេសន៍មានជាភាសាអង់គ្លេស និងខ្មែរ។[3]

បន្ទាប់ពីរៀបរៀងការសម្រាប់គម្រោងឧបត្ថម្ភសាងសង់បង្គន់អនាម័យ ក្រុមការងារវ៉ាយស៊ិ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ មានជំហានបន្ទាប់ក្នុងការសាកល្បងគម្រោងសម្រាប់ប្រាំគ្រួសារ។ របាយការណ៍នេះចងក្រងរាល់សកម្មភាព ដែលត្រូវបានអនុវត្តដើម្បីបើកដំណើរការ គម្រោងឧបត្ថម្ភសាងសង់បង្គន់អនាម័យ ហើយក្នុងនោះក៏ឆ្លុះបញ្ចាំងពីបញ្ហាប្រឈមមុខ និងលទ្ធផលដែលសម្រេចបាន។ តែរបាយការណ៍នេះមិនបានរៀបរាប់ពីការចុះតាមសហគមន៍ប្រចាំខែដើម្បីប្រមូលប្រាក់សងថ្លៃបង្គន់ និងពិនិត្យមើលលើការប្រើប្រាស់និងការថែទាំបង្គន់ និងមិនបានទទួលទិន្នន័យទាក់ទងនឹងស្ថានភាពហិរញ្ញវត្ថុរបស់គ្រួសារ ដែលទទួលប្រាក់ឧបត្ថម្ភ។ បញ្ហាដែលបានរៀបរាប់ខាងលើ នឹងកត់ត្រាក្នុងរបាយការណ៍បន្ទាប់។

## 1.1. គោលបំណងរបស់ការអនុវត្តគម្រោង

គោលបំណងនៃគម្រោងឧបត្ថម្ភសាងសង់បង្គន់អនាម័យ គឺដើម្បីឱ្យគ្រួសារក្រីក្រអាចមានលទ្ធភាពសាងសង់បង្គន់អនាម័យ។ គោលបំណងនៃការសាកល្បងគម្រោងភូមិភ្នំនេះ គឺបញ្ជាក់ពីលទ្ធភាពនៃគម្រោងឧបត្ថម្ភសាងសង់បង្គន់អនាម័យ។ ជាពិសេស គម្រោងសាកល្បងនេះមានគោលបំណងឆ្លើយសំណួរដូចខាងក្រោម៖

[3] មានពេលខ្លះ សកម្មភាពជាក់ស្តែងត្រូវបានអនុវត្តខុសពីការគ្រោងទុកដោយសារទទួលបានមតិយោបល់ពីក្រុមការងារអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ និងក្រុមការងារ ដែលបានអនុវឌ្ឍការងារផ្ទាល់ ព្រមទាំងស្ថានភាពប្រែប្រួលតាមជាក់ស្តែងអំឡុងពេលការអនុវត្តគម្រោង។

- តើលក្ខណវិនិច្ឆ័យ និងកម្រងសំនួរ មានលក្ខណៈល្អគ្រប់គ្រាន់ក្នុងការកំណត់គ្រួសារ ដែលពិតជាត្រូវជំនួយជាពិតប្រាកដ ស្របទៅនឹងភាពយុត្តិធម៌ និងគោលដៅរបស់គម្រោង។
- តើចំនួនប្រាក់បត្ថម្ភដែលបានផ្តល់ជូន ពិតជាសមស្របនឹងសមត្ថភាពនិងឆន្ទៈរបស់គ្រួសារក្រីក្រក្នុងការបង់សងមកវិញទេ?
- តើលក្ខខណ្ឌ នៃកិច្ចសន្យាបង់ប្រាក់ពិតជាមានប្រសិទ្ធភាពដែរឬទេ (ឧ. ប្រាក់សងប្រចាំខែមានភាពបទបែន)? តើយើងគួរតែកំណត់ចំនួនជាក់លាក់សម្រាប់ប្រាក់បង់សងដែរឬទេ? តើការបង់ប្រចាំខែយូរពេកឬខ្លីពេក? តើយើងមានវិធានការអ្វីប្រសិនបើគ្រួសារណាមួយមិនបានបង់ប្រាក់វិភាគទាន?
- តើដំណើរជ្រើសរើសអ្នកផ្គត់ផ្គង់សម្ភារសំណង់មាន ប្រសិទ្ធិភាពនិងប្រសិទ្ធិផលដែរឬទេ? តើអ្នកផ្គត់ផ្គង់ដែលបានជ្រើសរើសនោះអាចជឿទុកចិត្តបានទេ ហើយគេបានសាងសង់បង្គន់អនាម័យមានគុណភាពល្អទេ? តើក្រុមការងារវ៉ាយស៍ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍគួរតែជ្រើសយកអ្នកផ្គត់ផ្គង់ដដែលនេះសម្រាប់គម្រោងបន្ទាប់ដែរឬទេ?
- តើគ្រួសារដែលទទួលការឧបត្ថម្ភសាងបានប្រើប្រាស់បង្គន់អនាម័យ អំឡុងពេលសាកល្បងគម្រោងនេះដែរឬទេ? ហេតុអ្វីបានប្រើ និងហេតុអ្វីបានមិនប្រើ?
- តើក្រុមការងារវ៉ាយស៍ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍគួរតែធ្វើការកែសម្រួលអ្វីខ្លះលើគម្រោងឧបត្ថម្ភនេះ?

របាយការណ៍នេះអាចផ្តល់ជាឧបករណ៍ត្រិះរិះពិចារណាទៅលើសំនួរមួយចំនួន ខណៈដែលក្រុមការងារអនុវត្តគម្រោងតែងផ្តល់មតិយោបល់ស្ទើររៀងរាល់ថ្ងៃ។ សំនួរទាំងអស់នឹងត្រូវឆ្លើយពេញក្រោយពីដំណាក់កាលបង់ប្រាក់ និងត្រួតពិនិត្យបានបញ្ចប់ និងការវាយតម្លៃទើបតែបញ្ចប់។

## 1.2. កាលវិភាគ

សេចក្តីគ្រោងរបស់គម្រោងឧបត្ថម្ភសាងសង់បង្គន់អនាម័យនេះ បានចាប់ផ្តើមបង្កើតក្រោយពេលក្រុមការងារចុះសិក្សាក្នុងសហគមន៍ក្នុងខែតុលាឆ្នាំ ២០១៧។ ក្រុមការងារអង្គការនាគព័ន្ធសម្រាប់ការភិវឌ្ឍ បានត្រៀមលក្ខណៈជាមុនក្នុចាប់ផ្តើមគម្រោងឧបត្ថម្ភសាងសង់បង្គន់អនាម័យក្នុងខែមិថុនាឆ្នាំ ២០១៨ ប្រហែលពីរសប្តាហ៍មុនពេលចាប់ផ្តើមគម្រោង ធ្វើឱ្យការស្តភារការរៀបចំជាមួយនឹងប្រធានភូមិនិងមកទស្សនាសក្តានុពលសាងសង់នៅក្នុងព្រះធាតុស្រុក។ ក្រុមការងារ វ៉ាយស៍ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ មានវត្តមាន[4]ក្នុងភូមិភ្នំចាប់តាំងពី ថ្ងៃទី ១ ដល់ទី ១៩ ខែកក្កដា ២០១៨ (តារាងទី២)។ បន្ទាប់ពីក្រុមអនុវត្តន៍គម្រោងបានចេញពីភូមិភ្នំ ក្រុមការងារអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍបន្តត្រួតពិនិត្យមើលការសាងសង់រហូតដល់បង្គន់អនាម័យសាងសង់ចប់។

តារាងទី ១ កាលវិភាគនៅក្នុងភូមិភ្នំសម្រាប់បើកដំណើរការគម្រោងសាកល្បងគម្រោងឧបត្ថម្ភសាងសង់បង្គន់អនាម័យ។

| កាលបរិច្ឆេទ | សកម្មភាព | ទីតាំង |
|---|---|---|
| ថ្ងៃអាទិត្យទី ១ ខែកក្កដា | ធ្វើដំណើរពីភ្នំពេញទៅភូមិភ្នំ | |
| ថ្ងៃចន្ទទី ២ ខែកក្កដា | គម្រោងឧបត្ថម្ភដែលបានផ្សព្វផ្សាយ<br>នឹងគ្រួសារដែលបានចុះឈ្មោះ | ភូមិភ្នំ |
| ថ្ងៃទី ៣ ខែកក្កដា | ស្តង់បើកសម្រាប់ការចុះឈ្មោះ<br>ការរៀបចំសំភាសន៍រកគ្រួសារដែលអាចទទួលបានការឧបត្ថម្ភ | ផ្ទះរបស់អនុប្រធានភូមិ<br>ផ្ទះរបស់អនុប្រធានភូមិ |
| ថ្ងៃពុធទី ៤ ខែកក្កដា | សម្ភាសបេក្ខជន | ផ្ទះបេក្ខជន |
| ថ្ងៃទី ៥ ខែកក្កដា | សម្ភាសបេក្ខជន<br>ជ្រើសគ្រួសារដែលអាចទទួលការឧបត្ថម្ភ | ផ្ទះបេក្ខជន<br>ផ្ទះរបស់អនុប្រធានភូមិ |
| ថ្ងៃសុក្រទី ៦ ខែកក្កដា | ជ្រើសគ្រួសារដែលអាចទទួលការឧបត្ថម្ភ<br>គ្រួសារដែលជាប់ជាស្ថាពរ និងគ្រួសារមិនជាប់ | ផ្ទះរបស់អនុប្រធានភូមិ<br>ផ្ទះបេក្ខជន |
| ថ្ងៃសៅរ៍ ៧ ខែកក្កដា | គ្រួសារដែលជាប់ជាស្ថាពរ និងគ្រួសារមិនជាប់<br>ការរៀបចំសម្រាប់ពិធីចុះហត្ថលេខា | ផ្ទះបេក្ខជន<br>ផ្ទះរបស់អនុប្រធានភូមិ |
| ថ្ងៃអាទិត្យថ្ងៃ ៨ ខែកក្កដា | ពិធីចុះហត្ថលេខាកិច្ចព្រមព្រៀងទទួលយកគម្រោងឧបត្ថម្ភសាងសង់បង្គន់អនាម័យ | ផ្ទះរបស់អ្នកភូមិ<br>ផ្ទះរបស់អនុប្រធានភូមិ |

[4] អង្គការបណ្តុះបណ្តាលសហគមន៍ដើម្បីអភិវឌ្ឍន៍ (DARE) ដែលជាដៃគូក្នុងស្រុករបស់ វ៉ាយសិ មានវត្តមានក្នុងភូមិភ្នំពីថ្ងៃទី ១ ដល់ទី ៨ ខែកក្កដា ក្នុងនាមជាអ្នកសង្កេតការ។

| | ការវាយតម្លៃសំភារផ្គត់ផ្គង់ | |
|---|---|---|
| ថ្ងៃច័ន្ទ ៩ ខែកក្កដា | កិច្ចប្រជុំជាមួយនឹងអ្នកផ្គត់ផ្គង់សំភារ<br>កិច្ចប្រជុំជាមួយគ្រួសារដែលនឹងទទួលការឧបត្ថម្ភ | ផ្ទះរបស់ចុងភៅ<br>ផ្ទះរបស់គ្រួសារដែលនឹងទទួលការឧបត្ថម្ភ |
| ថ្ងៃទី ១០ ខែកក្កដា | កិច្ចប្រជុំជាមួយនឹងអ្នកផ្គត់ផ្គង់សំភារៈ<br>បានជួបមេឃុំ | ផ្ទះរបស់សុខរំ<br>ផ្ទះរបស់អនុប្រធានភូមិ |
| ថ្ងៃពុធទី ១១ ខែកក្កដា | ការត្រួតពិនិត្យសំណង់<br>ការចែករំលែកនៅលើការសង និងការថែទាំ | គ្រួសារដែលអាចទទួលការឧបត្ថម្ភ |
| ថ្ងៃទី ១២ ខែកក្កដា | ការត្រួតពិនិត្យសំណង់<br>ការចែករំលែកនៅលើការសង និងការថែទាំ | គ្រួសារដែលអាចទទួលការឧបត្ថម្ភ<br>គ្រួសារអ្នកទទួលបានការឧបត្ថម្ភ |
| ថ្ងៃសុក្រទី ១៣ ខែកក្កដា | ការត្រួតពិនិត្យសំណង់ | |
| ថ្ងៃសៅរ៍ទី ១៤ ខែកក្កដា | កិច្ចប្រជុំចុងក្រោយជាមួយនឹងអ្នកផ្គត់ផ្គង់សំភារៈ<br>ដំណើរពីភូមិភ្នំទៅភ្នំពេញ | ផ្ទះរបស់ស៊ីណា |

## 2. សកម្មភាព

ផ្នែកនេះពណ៌នាអំពីសកម្មភាពអនុវត្តដោយក្រុមការងារ វ៉ាយស៍និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ ដើម្បីចាប់ផ្តើមគម្រោងឧបត្ថម្ភសាងសង់បង្គន់អនាម័យ រួមទាំងការរៀបចំមុន និងក្រោយការសាងសង់បង្គន់ដើម្បីពិនិត្យមើលៈ អ្វីបានកើតឡើង បញ្ហាប្រឈមអ្វីខ្លះ និងមានលទ្ធផលសម្រេចអ្វីខ្លះ។ ផ្នែកទី៣ និង៤នឹងសង្ខេបពីបញ្ហាពិបាក និងលទ្ធផលដែលយើងបានជួបប្រទះ និងទទួលបាល។

កិច្ចការដែលត្រូវរៀបចំមុនពេលចាប់ផ្តើមគម្រោង មានដូចជាៈ ទាក់ទង សម្ភាស និងជ្រើសរើសអ្នកភូមិ ឬសហគ្រិន ដែលនឹងអាចសាងសង់បង្គន់អនាម័យបាន។ កិច្ចការដែលត្រូវធ្វើពេលផ្តើមគម្រោងឧបត្ថម្ភសាងសង់បង្គន់អនាម័យមានដូចជាៈ ការផ្សាយពីគម្រោង ការជ្រើសរើសអ្នកដែលអាចទទួលបានការឧបត្ថម្ភ និងការសង់បង្គន់។ ដោយហេតុតែបង្គន់សាងសង់មិនទាន់រួចមុនពេលក្រុមការងារចេញពីភូមិភ្នំ ក្រុមការងារអង្គការនាគព័ន្ធសម្រាប់ការអភីវឌ្ឍទទួលបន្ទុកត្រួតពិនិត្យការសាងសង់ ដែលនៅសល់ (រូបភាព ៥)។

ពេលបង្គន់សង់ហើយ ក្រុមការងារអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ និងវ៉ាយស៍បានចុះជួបគ្រួសារដែលទទូកការឧបត្ថម្ភជារាងរាល់ខែ ដើម្បីប្រមូលយកប្រាក់វិភាគទាន ត្រួតពិនិត្យការប្រើប្រាស់ និងការរក្សាបង្គន់ ព្រមទាំងប្រមូលទន្និន័យពីស្ថានភាពហរិញ្ញវត្ថុរបស់គ្រួសារ។ នៅពេលដំណាក់កាលបង់វិភាគទាន និងត្រួតពិនិត្យបានបញ្ចប់ ក្រុមការងារ វ៉ាយស៍ និងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍនឹងវាយតម្លៃពីគម្រោងសាកល្បងមួយនេះ។ សកម្មភាពទាំងនេះមិនបានរៀបរាប់ក្នុងរបាយការណ៍នេះទេ។

### 2.1. សកម្មភាពមុនចាប់ផ្តើមគម្រោង

មុនពេលផ្តើមគម្រោងឧបត្ថម្ភសាងសង់បង្គន់អនាម័យក្នុងភូមិភ្នំ ក្រុមការងារ វ៉ាយស៍ នឹងអង្គការនាព័ន្ធសម្រាប់ការអភិវឌ្ឍបានសំរិតសម្រាំងយកជាងបីនាក់ ដែលនឹងសង់បង្គន់ចំនួនប្រាំក្នុងភូមិ។ បន្ទាប់ពីយើងជ្រើសរើសគ្រួសារដែល ត្រូវនឹងទទួលការឧបត្ថម្ភហើយ ជាងសាងសង់ទាំងអស់ត្រូវធ្វើសម្រង់តម្លៃមកក្រុមការងារដើម្បីសម្រេចជាចុងក្រោយ។ គោលបំណងនៃការជ្រើសរើសជាងចំនួនបីនាក់(៣) គឺដើម្បីបង្កើនការប្រកួតប្រជែងហើយយើងក៏សង្ឃឹមថាទទួលបានប្រសិទ្ធិភាពចំណាយ។

| ដំណាក់ | សកម្មភាព | វិធីសាស្ត្រ |
|---|---|---|
| 1<br>ការស<br>ម្រាំងជ្រើសរើសអ្នកផ្គត់ផ្គង់ | ១. កំណត់ និងពិភាក្សាជាមួយអ្នកផ្គត់ផ្គង់<br>២. វាយតម្លៃ និងសម្រាំង អ្នកផ្គត់ផ្គង់បរិភាគី<br>៣. ជូនដំណឹងពីឈ្មោះអ្នកផ្គត់ផ្គង់ | ១.<br>កម្រងសំណួរសំរិតសម្រាំងដំបូង<br>២. ការវាយតម្លៃមុនការសម្រាំង<br>៣. កំណត់ចំណាំរបស់វាគ្មិន ITQ |
| 2<br>សេចក្តីប្រកាសពីគម្រោង | ១. ផ្សព្វផ្សាយពីកិច្ចប្រជុំសហគមន៍<br>២. បើកដំណើរការគម្រោងឧបត្ថម្ភ | ១. ប័ណ្ណឃោសនា<br>២. ឯកសារយោង<br>និងកំណត់ចំណាំរបស់វាគ្មិន |
| 3<br>កម្មវិធីដាក់ពាក្យទទួលការឧ<br>បត្ថម្ភពីគម្រោង | ១. បង្កើតស្តង់កម្មវិធីដាក់ពាក្យ<br>២. ប្រកាសពីបញ្ជីឈ្មោះបេក្ខជន | ១. ទម្រង់ចុះឈ្មោះ<br>២. បញ្ជីឈ្មោះបេក្ខជន<br>៣.<br>កម្រងសំនួរពិសិ<br>ទ្ធិទទួលបានការឧបត្ថម្ភ |
| 4<br>ការជ្រើសរើសបេក្ខជន | ១. សម្ភាសន៍បេក្ខជន<br>២. វាយតម្លៃនិងជ្រើសអ្នកទទួល ៥ នាក់<br>៣. ជូនដំណឹងទៅមេឃុំនិងមេភូមិ<br>៤. ប្រកាសបញ្ជីឈ្មោះអ្នកការទទួល<br>៥. ជូនដំណឹងអ្នកទទួល | ២.<br>ទម្រង់បែបបទវាយតម្លៃអ្នកទទួល<br>៣. បញ្ជីឈ្មោះអ្នកទទួល<br>៤. បញ្ជីឈ្មោះអ្នកទទួល<br>៥. កំណត់ចំណាំរបស់វាគ្មិន |
| 5<br>ការជ្រើសរើសអ្នកផ្គត់ផ្គង់<br>សេចក្តីបញ្ជាក់ពីអ្នកទទួល | ១. កិច្ចប្រជុំតាមតំបន់<br>២. ការដាក់ស្នើសម្រង់តម្លៃ<br>៣. វាយតម្លៃ និងជ្រើសអ្នកផ្គត់ផ្គង់<br>៤. បញ្ជាក់ការចូលរួមពីអ្នកទទួល | ១. បញ្ជីផ្ទៀងផ្ទាត់ពីការពិភាក្សា<br>និងITQ<br>២. N/A<br>៣. ឧបករណ៍វិភាគពីសម្រង់តម្លៃ<br>៤. កិច្ចព្រមព្រៀងរបស់អ្នកទទួល |
| 6<br>ការសាងសង់បង្គន់ | ១. អ្នកផ្គត់ផ្គង់សាងសង់បង្គន់<br>២. យល់ព្រមលើប្រាក់សន្សំ<br>និងរបៀបរៀបបង់ប្រាក់<br>៣. ណែនាំអ្នកទទួល | សរសេររបាយការណ៍ការវត្តគ<br>ម្រោង<br>២. N/A<br>៣.<br>ឯកសារយោងស |
| 7<br>ការបង់សង<br>និងការត្រួតពិនិត្យ | ១. ការប្រមូលប្រាក់សំណង<br>២.<br>ប្រមូលព័ត៌មានហិរញ្ញវត្ថុរបស់គ្រួសារនីមួយៗ<br>៣. ត្រួតពិនិត្យការប្រើប្រាស់<br>និងការថែរក្សាបង្គន់ | ១. ទម្រង់កំណត់ត្រានៃការបងសង<br>២. កំណត់ហេតុហិរញ្ញវត្ថុប្រចាំថ្ងៃ<br>៣. ទម្រង់នៃការត្រួតពិនិត្យបង្គន់ |
| 8<br>ការវាយតម្លៃ | ១. វាយតម្លៃគម្រោងសាកល្បង | ១.នឹងគ្រោងលើកក្រោយ |

រូបភាព ៥ផែនការអនុវត្តដើម។ មានការប្រែប្រួលខ្លះចំពោះផែនការអំឡុងពេលអនុវត្ត។

ដូច្នេះហើយ ពីរសប្តាហ៍មុនពេលក្រុមការងារអនុវត្តទាំងអស់ចុះដល់ភូមិភ្នំដើម្បីបើកដំណើរការគម្រោងឧបត្ថម្ភបង្គន់អនាម័យ អង្គការនាគព័ន្ធដើម្បីការអភិវឌ្ឍ (NOD) ចាប់ផ្តើមចុះតាមគ្រួសារនីមួយៗ និងចរចារជាមួយជាងសាងសង់ក្នុងស្រុកព្រះធាតុ (ក្រុមការងារ វាយស៍ក៏ចូលរួមជាមួយ NOD ដែរ) (រូបភាព៦)។ NOD បានណែនាំពីគម្រោងអនាម័យភូមិភ្នំ និងបានសួរសំណួរទាក់ទងនឹងសមត្ថភាពបច្ចេកទេសសាងសង់របស់ជាង ប្រសិទ្ធិភាពចំណាយ និងសេវាកម្មអតិថិជន ដោយប្រើកម្រងសំណួរសំរិតសម្រាំងដំបូង។



រូបភាព ៦ សម្ភាសន៍ជាងសាងសង់(📸លោកអ៊ុំ អ៊ីរ៉ូ)

ក៏ប៉ុន្តែ ជាងសាងសង់ជាច្រើនបានប្រាប់ថារវល់ពេកចូលរួមមិនបានអំឡុងនោះក៏ត្រូវជាពេលយុទ្ធនាការឃោសនាការបោះឆ្នោតផងដែរ។ នៅទីបញ្ចប់ នៅសល់តែជាងសាងសង់ពីរ(២)នាក់ ដែលទទួលយកគម្រោងសាងសង់បង្គន់នោះ។

## 2.2. ការផ្សព្វផ្សាយពីគម្រោងឧបត្ថមសង់បង្គន់ដល់ប្រជាពលរដ្ឋ

សកម្មភាពទាំងអស់ចាប់ផ្តើមមួយថ្ងៃបន្ទាប់ពីក្រុមការងារ វាយស៍ និង NOD មកដល់សហាគមន៍នៅថ្ងៃទី ០១ ខែកក្កដាឆ្នាំ ២០១៨ ហើយសកម្មភាពការងារទាំងឡាយផ្តើមដំណើរការនៅថ្ងៃបន្ទាប់។ ជំហានដំបូងគឺផ្សព្វផ្សាយនិងពន្យល់ពីកម្មវិធីបត្ថម្ភសាងសង់បង្គន់ទៅកាន់គ្រួសារជាច្រើនដែរអាចធ្វើបាន ដូច្នេះទើបគ្រួសារក្រីក្រមានសិទ្ធអាចដាក់ពាក្យសុំបាន។

ដំបូងអង្គការវាយស៍ (WISE) បានស្នើរៀបចំកិច្ចប្រជុំក្នុងសហាគមន៍ដើម្បីពន្យល់កម្មវិធីបត្ថម្ភសាងសង់បង្គន់និងចែកប័ណ្ណពត៌មានទូទាំងភូមិដើម្បីឲ្យប្រជាជនបានដឹងពីកិច្ចប្រជុំនេះ។ ក៏ប៉ុន្តែពេលមកដល់ផ្ទាល់ក្នុងភូមិភ្នំនឹងបានពិភាក្សាសំណើនេះជាមួយនឹងអង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ (NOD) និងសមាជិកវាយស៍ (WISE) ក្រុមការងារអនុវត្តម្រោង បានឲ្យដឹងថាវិធីសាស្រ្តនេះនឹងមិនអាចជ្រៀបដល់គ្រួសារក្រីក្សាបានទេ ព្រោះគ្រួសារក្រីក្រទាំងអស់នឹងមិនអាចដំណឹងនៃគម្រោងនេះ។

ក្រុមការងារនាគព័ន្ធ និងវាយបានសម្រេចចិត្តទៅទស្សនាគ្រួសារនីមួយៗដើម្បីពន្យល់ពីគម្រោងឧបត្ថម្ភសាងសង់បង្គន់ និងអញ្ជើញគ្រួសារទាំងនោះដាក់ពាក្យសុំ។ ភ្នំភូមិតែមាន ១០១ គ្រួសារប៉ុននោះដូច្នេះហើយ វិធីសាស្រ្តនេះអាចអនុវត្តបានធម្មតា។ ក្រុមការងារវាយកម្ពុជា () បែងចែកជាពីរ (២) ក្រុម ដោយក្នុងក្រុមនីមួយៗមានសមាជិកបី(៣) នាក់ ដើម្បីចុះតាមផ្ទះនិមួយៗតាមបណ្តោយថ្នល់ជាតិ។ តាមផ្ទះនីមួយៗ ក្រុមការងារយើងនឹងពន្យល់ជាលម្អិតនូវគម្រោងឧបត្ថម្ភសាងសង់បង្គន់ (រូប ៧) ដោយបញ្ជាក់ពីចំនួនទឹកប្រាក់វិភាគទាន ដែលគ្រួសារទទួលបានការឧបត្ថម្ភត្រូវចូលរួមចំណែក (២០%នៃទឹកប្រាក់ចំណាយសាងសង់ទាំងអស់ អតិបរមា ៦០ ដុល្លារអាមេរិក) លើសពីនេះទៅទៀតក្រុមការងារក៏បញ្ជាក់ពី ឯកសារចាំបាច់ លក្ខខណ្ឌ និងដំណើរការជ្រើសរើស (ប័ណ្ណក្រីក្រ ទំហំនិងគុណភាពផ្ទះ ចំណូលចំណាយក្នុងគ្រួសារ មធ្យោបាយធ្វើដំណើរ គោក្របីនិងដីស្រែ ) ព្រមទាំងរបៀបដាក់ពាក្យ ការជ្រើសរើស និងការសាងសង់បង្គន់។



រូបភាព ៧ ចែករំលែកពត៌មានពីកម្មវិធីឧបត្ថម្ភសាងសង់បង្គន់ (📸Intan Rahmita Adiputri)

ដើម្បីបញ្ចប់ការផ្សព្វផ្សាយគម្រោងកាន់តែរហ័យ ក្រុមការងារអនុវត្តគម្រោងសម្រេចចិត្តចុះតាមគ្រួសារណាដែលក្រុមយើងសង្កេតឃើញថាក្រីក្រ ដោយផ្អែកលើទំហំនិងគុណភាពផ្ទះ ដែលមិនមានបង្គន់។ តែអ្វីដែលជាបញ្ហាប្រឈមនោះគឺថា ក្រុមការងារយើងអាចវិនិច្ឆ័យខុសលើស្ថានភាពគ្រួសារក្រីក្រ។ បញ្ហាជាក់ស្តែងកើតមានបន្ទាប់ពីអ្នកភូមិម្នាក់មកជួបផ្ទាល់ជាមួយក្រុមការងារអនុវត្តគម្រោងយើង ដើម្បីមកដាក់ពាក់សុំគម្រោងឧបត្ថម្ភធ្វើបង្គន់ ។ គាត់គិតថាបង្គន់អនាម័យនឹងសាងសង់ក្នុងទម្រង់សន្លឹកស័ង្កសីដែលអាចឲ្យសមាជិកគ្រួសារគាត់ងូតទឹកខាងក្នុងនោះបាន។

ដោយក្រុមការងារអនុវត្តគម្រោងបានសំណេះសំណាលផ្ទាល់ជាមួយអ្នកភូមិ យើងបានសុំពត៌មានលម្អិតពីពួកគាត់នៅតាមផ្ទះនីមួយៗប្រសិនពួកគាត់មានចំណាប់អារម្មណ៍ចង់ដាក់ពាក្យសុំ (ឈ្មោះ លេខទូរស័ព្ទ អាស័យដ្ឋាន និងរូបថត) (រូបភាព ៨)។ (ចំនុចនេះខុសពីគម្រោងដំបូងដែលថាយើងនឹងដាក់បញ្ជីរនៅផ្ទះអនុភូមិក្រោយពីការប្រជុំចប់)។




រូបភាព ៨ ពត៌មានលម្អិតរបស់អ្នកដាក់ពាក្យត្រូវបានកត់ត្រាក្នុងពាក្យចុះឈ្មោះ(📸Andry Hamida)

អ្នកស្រុកមួយចំនួនរៀងស្ទាក់ស្ទើរអំពីដាក់ពាក្យសុំ ដោយសារគាត់មិនប្រាកដថាតើគាត់អាចសងវិភាគទាន ២០% នៃប្រាក់សាងសង់បង្គន់។ អ្នកភូមិផ្សេងទៀតត្រូវការពេលវេលាដើម្បីពិចារណា ឬចង់ទៅពិភាក្សាជាមួយកាប្តី និង/ឬ សមាជិកគ្រួសារខ្លួនសិន។ ក្រុមការងាររបស់យើងណែរណាំឲ្យអ្នកភូមិទាំងនោះទៅជួបផ្ទាល់នៅផ្ទះរបស់អនុប្រធានភូមិនៅថ្ងៃបន្ទាប់ បើពួកគាត់សម្រេចចុះឈ្មោះ។ គ្មានអ្នកភូមិមកទេ។ ក្រុមការងារយើងក៏មិនច្បាស់ដែរថាតើទាំងគ្រួសារទាំងនោះមិនចង់បានការឧបត្ថម្ភ មិនមានពេលវេលាឬមធ្យោបាយធ្វើដំណើរមកផ្ទះអនុភូមិ ឬត្រូវបានគំរាមកំហែងមិនឲ្យមកក្រោមទម្រង់ណាមួយ។

ការផ្សព្វផ្សាយគម្រោងបត្ថម្ភសាងសង់បង្គន់ចំណាយពេលមួយថ្ងៃកន្លះ។ ក្រុមការងារយើងបានចំណាយពេលមួយថ្ងៃដំបូងដើរពេញភូមិភ្នំ ប៉ុន្តែដោយហេតុតែអ្នកភូមិខ្លះមិននៅផ្ទះ ក្រុមការងារយើងត្រឡប់មកម្តងទៀតនៅព្រឹកស្អែកដើម្បីជួបគ្រួសារដែលមិនបានជួបពីមុន។ មាន ១៤ គ្រួសារបានដាក់ពាក្យសុំការឧបត្ថម្ភ[5]។

## 2.3. ការជ្រើសរើសគ្រួសារដែលទទួលបានការឧបត្ថម្ភ

ក្នុងចំណោមបេក្ខជន ១៤ គ្រួសារ ក្រុមការងារនាគព័ន្ធសម្រាប់ការអភិវឌ្ឍ (NOD) និងវ៉ាយស៍ (WISE) បានកំណត់បេក្ខជន ដែលនឹងត្រូវទទួលបានការឧបត្ថម្ភឬបង្គន់អនាម័យ និងបានជ្រើសយកបេក្ខជនចុងក្រោយប្រាំ(៥) នាក់ ដែលស័ក្កសមទទួលការឧបត្ថម្ភ។ ដើម្បីធ្វើដូច្នេះបាន ក្រុមការងារអនុវត្តគម្រោង បានជួបសម្ភាសន៍ជាមួយបេក្ខជនទាំងអស់ មុនពេលចាប់ផ្តើមដំណើរការជ្រើសរើស។

### 2.3.1. ការសម្ភាសបេក្ខជន

ដើម្បីសំភាសន៍បេក្ខជន ក្រុមការងារវ៉ាយស៍ បួន (៤) នាក់បានបែងចែកជាពីរ (២) គូ ដោយក្នុងគូនីមួយៗម្នាក់សួរសំនួរ ហើយម្នាក់កត់ត្រា (រូបភាព ៩)។ ការសម្ភាសន៍សួរទៅតាមសំណួរទាក់ទងនឹងលក្ខខណ្ឌ ដែលក្រុមកាងារវ៉ាយស៍ (WISE) បានសរសេរ ក្នុងគោលបំណងប្រមូលព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិលក្ខខណ្ឌរបស់គ្រួសារបេក្ខជនដែលបានបំពេញពាក្យសុំ ព្រមទាំងបញ្ហាប្រឈមក្នុងការសាងសង់បង្គន់។ ផ្នែកនានាក្នុងកម្រងសំណួរមានដូចជា៖ ព័ត៌មានរបស់បេក្ខជនបណ្តៅក្រីក្រ កម្មសិទ្ធិ និងគុណភាពផ្ទះ ចំណូលនិងចំណាយក្នុងគ្រួសារ មធ្យោបាយធ្វើដំណើរ គោក្របី ដីស្រែ ពិការភាព ជំងឺឬបញ្ហាប្រឈមកាយសម្បទា ពត៌មានពីការផ្ទេរបង្គន់ និងការប្តេជ្ញាចិត្តធ្វើឲ្យប្រសើរឡើងនូវអនាម័យ។ សម្ភាសន៍ក៏បានរំលឹកឡើងវិញរបស់បេលខុសត្រូវសងរបស់ពួកគេ

[5] ក្រុមការងារវ៉ាយស៍ (WISE) ដំបូងគិតថាចង់ប្រកាសបញ្ជីឈ្មោះបេក្ខជនជុំវិញភូមិភ្នំ។ គោលបំណងគឺយើងមិនចង់ឲ្យគ្រួសារដែលមិនមានគ្រប់លក្ខខណ្ឌចំណាយពេលបន្តដាក់ពាក្យសុំ។ ទោះជាយ៉ាងក្តី ក្រុមការងារយើងមិនបានធ្វើដូច្នេះទេព្រោះ ការប្រកាសឈ្មោះបែបនឹងអាចបណ្តាលឱ្យគ្រួសារបេក្ខជនមិនសប្បាយចិត្ត។

២០%ការរួមចំណែកទៅឋានសំណង់ការចំណាយប្រសិនបើពួកគេត្រូវបានជ្រើស,ហើយថាក់ក្បាល/ប្រាជ្ញានឹងមិនសាងសង់ណាមួយទៀតឬប្រសិនបើពួកគេមិនបានបញ្ចប់ការសបស់ពួកគេរួមចំណែក។



រូបភាព ៩ ការសម្ភាសបេក្ខជន(📸Andry Hamida)

ដំណើរសម្ភាសប្រើពេលជាងមួយ(១) ថ្ងៃ។ បេក្ខជន១១នាក់ត្រូវបានសម្ភាសនៅលើថ្ងៃដំបូង(៤ កក្កដា ២០១៨) និងនៅសល់បី(៣) នាក់ទៀតត្រូវបានសម្ភាសនិនៅព្រឹកថ្ងៃទីពីរ(៥ ខែកក្កដាឆ្នាំ ២០១៨)។ បញ្ហាប្រឈមមួយចំនួនបានលេចឡើងអំឡុងពេលសំភាសន៍។ យើងពិបាកកំណត់បេក្ខជនមួយចំនួនព្រោះពួកគាត់មិននៅផ្ទះនិងមិនមានទូរស័ព្ទទាក់ទង។ ដំបូងអ្នកសម្ភាសន៍ពិបាកនិយាយឆ្លងឆ្លើយជាមួយកាន់បេក្ខជន ព្រោះគ្រៀមភាសាក្នុងតំបន់ខុសប្លែកពីភាសាទូទៅ។ ក្រោយមក អ្នកសម្ភាសន៍បានសម្របខ្លួនជាមួយភាសាទាំងនោះ បន្ទាប់បានសម្ភាសន៍មួយរយៈមក[6]។ អ្នកសម្ភាសមួយក្រុមជួបប្រទះអ្នកដាក់ពាក្យម្នាក់ ដែលស្រវឹងហើយបែជាមិនស្វាគមន៍ ក្រុមការងារវាយស៍និងនាគព័ន្ធ (WISE/NOD) ដូចនេះយើងខ្វះលទ្ធផលខ្លះក្នុងភូមិភ្នំ។

ដំណើរការសម្ភាសបេក្ខជននេះក៏បង្ហាញថាកម្រងសំនួរនៅមានចំនុចខ្វះចន្លោះ ដែលនឹងអាចដោះស្រាយនៅពេលក្រោយប្រសិនគម្រោងបត្តម្ភសាងសង់បង្គន់នេះត្រូវបានពង្រីកវិសាលភាព។ ឧទាហរណ៍៖

- បេក្ខជនមួយចំនួនបានចែករំលែកពត៌មានអំពីកម្ចីធនាគារ ដែលពួកគេបានយក និងបំណុលពីមុនដែលគាត់មិនទាន់សងរួច អ្វីទាំងនេះហើយដែលកម្រងសំនួរយើងមិនបានបញ្ចូល។
- គ្រួសារចិញ្ចឹមសត្វដូចជាសត្វមាន់និងទា ប៉ុន្តែកម្រងសំណួរមានតែសត្វគោទេ។ គ្រួសារខ្លះមិនមែនជាម្ចាស់សត្វចញ្ចឹមទេគាត់គ្រាន់តែខ្ចីឬ ស៊ីឈ្នួលមើលគោក្របីឲ្យគេតែប៉ុននោះ។
- កម្រងសំណួររបស់យើងសួរតែអំពីដីស្រែទេ តែអ្នកភូមិក៏ដាំដំណាំផ្សេងៗទៀតសម្រាប់ជីវភាពគាត់ផងដែរ។

### 2.3.2. ការជ្រើសរើសគ្រួសារដែលទទួលបានការឧបត្ថម្ភ

បន្ទាប់ពីការប្រមូលព័ត៌មានពាក់ព័ន្ធ រួចមកក្រុមការងារគម្រោងបានបន្តធ្វើការវាយតម្លៃនិងជ្រើសគ្រួសារដែលត្រូវទទួលការឧបត្ថម្ភ។

[6] អ្នកសម្ភាសន៍គ្រប់រូបត្រៀមខ្លួនបានរួចរាល់ព្រោះពួកគាត់ចំណាយពេលមួយថ្ងៃមុនហ្វឹកហាត់ការសម្ភាសន៍នេះ។

ការពិភាក្សាជ្រើសរើសបេក្ខជនធ្វើដោយក្រុមការងារសរុបដប់(១០) នាក់នៅភូមិភ្នំ(រូបភាព ១០)។ ក្រៅពីមានសមាជិកវ៉ាយស៍នៅកម្ពុជាយើងក៏មានសមាជិកមកពីឥណ្ឌូនេស៊ីនិងសិង្ហបុរី ព្រមទាំងដំណាងអង្គការដៃគូក្នុងស្រុកមានដូចជាអង្គការបណ្តុះបណ្តាលសហគមន៍ដើម្បីអភិវឌ្ឍន៍(អតីតអង្គការ DARE)[7]។



រូបភាព ១០ ការពិភាក្សាជ្រើសរើសបេក្ខជន(📸Intan Rahmita Adiputri)

ក្រុមការងារវ៉ាយស៍មិនបានដាក់ចេញមុននូវរបៀបវារៈជ្រើសរើសនោះទេ ព្រោះអីយើងមិនទាន់ដឹងច្បាស់ថាតើមានប៉ុន្មានគ្រួសារ ដែលនឹងដាក់ពាក្យនិងអ្នកណាខ្លះនឹងចូលរួមក្នុងការជ្រើសរើសគ្រួសារទទួលការឧបត្ថម្ភ។ ក្រុមការងារវ៉ាយស៍() បានត្រឹមតែបង្កើតប្រព័ន្ធដាក់ពន្ទុកដើម្បីវាយតម្លៃសមាសភាពនិង លក្ខខណ្ឌទទួលការឧបត្ថម្ភធនធាន។ ដូច្នេះ ក្រុមការងាររបស់យើងបានសម្រេចបែងចែកដំណាក់កាលជ្រើសរើសជាបីដំណាក់ផ្សេងៗគ្នា ដោយយោងទៅតាមស្ថានភាពជាក់ស្តែងអំឡុងពេលអនុវត្តគម្រោង៖

1. ក្រុមសម្ភាសន៍នីមួយៗវាយតម្លៃបេក្ខជន និងស្នើរជម្រុសបេក្ខជនណា ដែលមិនមានលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ទទួលយកការឧបត្ថម្ភ
2. គណកម្មាធិការជ្រើសរើសបានជ្រើសយកបេក្ខជនប្រាំ (៥) គ្រួសារក្នុងចំណោមគ្រួសារទាំងអស់ ដែលបានដាក់ពាក្យ។
3. គណកម្មាធិការជ្រើសរើសបានសម្រេចថាតើគ្រួសារណាគួទទួលធនធានឧបត្ថម្ភ ៨០% ឬគ្រួសារណាគួរទទួល ១០០ %។

#### 2.3.2.1. ជម្រុះបេក្ខជនណាដែលមិនគ្រប់លក្ខខណ្ឌ។

បន្ទាប់ពីការប្រមូលព័ត៌មានពាក់ព័ន្ធបានហើយមក ក្រុមការងារបន្តវាយតម្លៃសមាសភាពនិងលក្ខខណ្ឌរបស់បេក្ខជននីមួយៗ ធ្វើដូច្នេះដើម្បីឱ្យគ្រួសារដែលគ្រប់លក្ខខណ្ឌអាចដកចេញពីការពិចារណាបាន។ ការវាយតម្លៃត្រូវបានអនុវត្តដោយសមាជិកក្រុមដែលបានសម្ភាសបេក្ខជន ដោយសារពួកគាត់ដឹងពីស្ថានភាពគ្រួសារថានច្បាស់។

នៅចុងបញ្ចប់នៃកម្រងសំណួរជ្រើសរើសបេក្ខជន ក្រុមការងារវ៉ាយស៍ (WISE) បាននប្រាជ្ញាបានបង្កើតប្រព័ន្ធដាក់ពិន្ទុ សម្រាប់ជួយគណកម្មាធិការជ្រើសរើសសម្រេចចិត្តលើថាតើគ្រួសារណាសមនឹងទទួលការឧបត្ថម្ភ(តារាង ២)។ ប៉ុន្តែការ ដោយយល់ឃើញថាប្រព័ន្ធពិន្ទុនិងប្រព័ន្ធលក្ខខណ្ឌជ្រើសរើសទាំងនោះមិនឆ្លុះបញ្ចាំងពីស្ថានគ្រួសារនោះទេ

[7] អង្គការនាគព័ន្ធសម្រាប់ការអភិវឌ្ឍ (NOD) មិនមានវត្តមានពេលយើងកំពុងជ្រើសគ្រួសារដែលនឹងទទួលការឧបត្ថម្ភនោះទេ។

ដូច្នេះគណកម្មាធិការជ្រើសរើសក៏ធ្វើការសម្រេចចិត្ត ដែលមិនមានក្នុងប្រព័ន្ធដាក់ពិន្ទុមានស្រាប់ដំរាប់ណាដំណើរការយុត្តិកម្មនៅតែមានភាពសមស្របនឹងភាពជាក់ស្តែង។ ឧទាហរណ៍ដូចរៀបរាប់នៅក្នុងផ្នែកទី ២ ទី៣ ទី១ ការវិនិច្ឆ័យមិនបានពិចារណាលើស្ថានភាពបំណុលនិងកម្ចីក្នុងគ្រួសារ សត្វក្រៅពីគោក្របី ព្រមទាំងដីស្រែដែលជាកម្មសិទ្ធិរបស់គ្រួសារ។

តារាងទី ២ តារាងវាយតម្លៃសមាសភាពទទួលការឧបត្ថម្ភ

<table>
<tr><th>ក្បាន</th><th>លក្ខខណ្ឌវិនិច្ឆ័យ</th><th>មិនជាប់</th><th>ជាប់</th></tr>
<tr><td>1</td><td>គ្រួសារកាន់ប័ណ្ណសមធម៌មានសុពលភាព(ប័ណ្ណក្រីក្រ)។ ប្រសិនបើC01b = 99<br>យើងផ្ទៀងផ្ទាត់ជាមួយនឹងប្រធានភូមិ ថាតើគ្រួសារនេះមានប័ណ្ណក្រីក្រ<br>បន្ទាប់ផ្ទៀបថ្មីប្បន្នភាពចំនុច C01c ជាមួយនឹងចម្លើយត្រឹមត្រូវ។<br>ប្រសិនបើមានភាពខុសគ្នារវាងចម្លើយ C01a និង C01c<br>យើងកំណត់ថាតើភាពខុសគ្នានេះប៉ះពាល់ដល់ដំណើរការដាក់ពាក្យសុំរបស់បេក្ខជនយ៉ាងដូចម្តេច។</td><td>ពិន្ទុ 0</td><td>ពិន្ទុ ១</td></tr>
<tr><td>2</td><td>បេក្ខជនមិនមានផ្ទះផ្ទាល់ខ្លួន ឬផ្ទះសាងសង់ក្នុងបរិវេនដីតិចជាង ៩×៩ម៉ែត្រ<br>និងផ្ទះធ្វើមកពីស្បូវ ឬស្លឹកត្នោត។ ក្នុងករណីដែលហេតុផលបេក្ខជនជាប់<br>ឬមិនជាប់ក្នុងលក្ខខណ្ឌណាមួយដែលមិនមានក្នុងប្រព័ន្ធដាក់ពិន្ទុទេ<br>សូមបកស្រាយហេតុផលទាំងនោះនៅចំនុចនេះ។</td><td>ពិន្ទុ<១</td><td>ពិន្ទុ≥១</td></tr>
